**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៥ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# វិធានការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៦/០០២ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីវិធានការហាមឃាត់ ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណង ៖

- ចូលរួមក្នុងការការពារសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- បង្កើនប្រសិទ្ធភាពត្រួតពិនិត្យលើការផ្សព្វផ្សាយផលិតផលថ្នាំជក់
- ទប់ស្កាត់រាល់មធ្យោបាយផ្សព្វផ្សាយដែលទាក់ទាញអតិថិជន ឱ្យប្រើប្រាស់ផលិតផលថ្នាំជក់
- កាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់
- កាត់បន្ថយផលប៉ះពាល់នៃការប្រើប្រាស់ផលិតផលថ្នាំជក់ ទៅលើសុខភាព បរិស្ថាន សេដ្ឋកិច្ច និងសង្គម។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៤.-**

ក្រសួងសុខាភិបាល ជាស្ថាប័នមានសមត្ថកិច្ចក្នុងការណែនាំ និងត្រួតពិនិត្យការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាពជាសេនាធិការ។ ក្នុងករណីចាំបាច់ ក្រសួងសុខាភិបាលត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ច។

## ជំពូកទី៣

## វិធានការចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់

**មាត្រា ៥.-**

ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ តាមប្រព័ន្ធផ្សព្វផ្សាយជារូបភាព ឬជាអក្សរ ឬជាសំឡេង តាមរយៈវិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី ស៊ីឌី វីស៊ីឌី ឌីវីឌី និងតាមសេវាទូរគមនាគមន៍ផ្សេងៗទៀត ត្រូវហាមឃាត់។

**មាត្រា ៦.-**

ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ជាផ្ទាំងរូបភាព ផ្ទាំងប៉ាណូ ផ្ទាំងបដា ផ្ទាំងគំនូរ ឬបណ្តាញផ្សព្វផ្សាយផលិតផលថ្នាំជក់ផ្សេងៗទៀត ជាសាធារណៈ និងការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ ជារូបភាពចល័ត នៅលើជញ្ជាំងរថយន្ត ឬលើយានជំនិះគ្រប់ប្រភេទ ត្រូវហាមឃាត់។ ចំពោះការដាក់តាំងបង្ហាញ ឬការបិទរូបសញ្ញា ឬឈ្មោះផលិតផលថ្នាំជក់ អាចធ្វើទៅបានតែនៅទីកន្លែងលក់ ឬតូបលក់ ឬក្នុងហាងលក់បារីផ្ទាល់តែប៉ុណ្ណោះ។

ទំហំ និងចំនួនរូបសញ្ញា ឬឈ្មោះផលិតផលថ្នាំជក់ ដែលដាក់តាំងបង្ហាញ ឬបិទនៅទីកន្លែងលក់ ឬតូបលក់ ឬក្នុងហាងលក់បារី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា ៧.-**

ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ដល់សាធារណជន នៅតាមទីកន្លែងសាធារណៈណាមួយ ដូចជាក្នុងកម្មវិធីប្រគំតន្ត្រី ឬកម្មវិធីកីឡា ឬកម្មវិធីផ្សេងៗទៀត និងការផ្សព្វផ្សាយផលិតផលថ្នាំជក់ ដល់អតិថិជនដោយផ្ទាល់ ដោយភ្នាក់ងារក្រុមហ៊ុនផលិតថ្នាំជក់ ត្រូវហាមឃាត់។

**មាត្រា ៨.-**

ការឧបត្ថម្ភកម្មវិធីក្នុងការប្រគំតន្ត្រី ឬកម្មវិធីកីឡា ឬកម្មវិធីជាសាធារណៈផ្សេងៗទៀត ជាផលិតផលថ្នាំជក់ ឬជាសម្ភារៈដែលបង្ហាញពីឈ្មោះផលិតផលថ្នាំជក់ ត្រូវហាមឃាត់ លើកលែងតែការឧបត្ថម្ភជាសម្ភារៈ ឬជាថវិកា ក្នុងសកម្មភាពមនុស្សធម៌ ឬសកម្មភាពជាប្រយោជន៍ដល់សង្គមជាតិ ដែលមិនបង្ហាញពីចេតនាកេងយកចំណេញផ្នែកពាណិជ្ជកម្ម ឬការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់។

**មាត្រា ៩.-**

គ្រប់បណ្តាញផ្សព្វផ្សាយទាំងអស់ ត្រូវចូលរួមសហការអនុវត្តមាត្រា៥ មាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យនេះ។

## ជំពូកទី៤

## ទណ្ឌកម្ម

**មាត្រា ១០.-**

ក្រុមហ៊ុនថ្នាំជក់ ផលិតករក្នុងស្រុក អ្នកនាំចូលផលិតផលថ្នាំជក់ អាជីវករ អ្នកពាក់ព័ន្ធនឹងការផ្សព្វផ្សាយ និងអ្នកចែកចាយផលិតផលថ្នាំជក់ ដែលមិនគោរពបទប្បញ្ញត្តិនៃអនុក្រឹត្យនេះត្រូវទទួលទណ្ឌកម្មដូចតទៅ៖

-ព្រមានជាលាយលក្ខណ៍អក្សរ



-ដកហូតផ្ទាំងរូបភាព ផ្ទាំងប៉ាណូ ផ្ទាំងបដា ផ្ទាំងគំនូរ ឬបណ្ណផ្សព្វផ្សាយផលិតផលថ្នាំជក់ផ្សេងៗទៀត

-ផ្អាកការប្រកបអាជីវកម្មជាបណ្តោះអាសន្ន

-បិទអាជីវកម្មជាស្ថាពរ ក្នុងករណីមិនរាងចាល ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**មាត្រា ១១.-**

បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមានរយៈពេល០៦(ប្រាំមួយ)ខែ ក្រុមហ៊ុនថ្នាំជក់ ផលិតករក្នុងស្រុក អ្នកនាំចូលផលិតផលថ្នាំជក់ អាជីវករ អ្នកពាក់ព័ន្ធនឹងការផ្សព្វផ្សាយ និងអ្នកចែកចាយផលិតផលថ្នាំជក់ ដែលកំពុងផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់របស់ខ្លួន ត្រូវបញ្ឈប់ការផ្សាយពាណិជ្ជកម្មនេះ ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែកុម្ភៈ ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា ១៣

-រាជកិច្ច

-ឯកសារ- កាលប្បវត្តិ